២០២០
ឯកសារ
គោលនយោបាយ
សង្ខេប

# ការគ្រប់គ្រង សំណល់រឹង នៅក្នុងខេត្តកែប




*គម្របរូបភាព: រូបសំណាកក្តាមនៅខេត្តកែប (Christopher Godlove 2019)*

គ.ជ.អ.ប
NCDD

The Asia Foundation

# សេចក្តីផ្តើម

## ការគ្រប់គ្រងសំណល់រឹងជាអាទិភាពមួយសម្រាប់កម្ពុជា

ការគ្រប់គ្រងសំណល់រឹងនៅទីប្រជុំជន បានក្លាយទៅជាបញ្ហាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ តាមការប៉ាន់ប្រមាណ ក្នុងឆ្នាំ២០១៧ នៅទូទាំងប្រទេសកម្ពុជា បរិមាណសំណល់រឹងទីប្រជុំជន គឺ ៣,៦៥ លានតោន ច្រើនជាង ០៣ ដងនៃបរិមាណសំណល់កាលពី ០៣ ឆ្នាំមុន ដែលមានប្រមាណ ១ លានតោន ក្នុងឆ្នាំ២០១៤ (Modak et al., 2017; Pech, 2018)។ ការកើនឡើងបរិមាណសំរាមយ៉ាងខ្លាំងនេះ គឺបណ្តាលមកពីកត្តាជាច្រើនដូចជា កំណើនប្រជាជនយ៉ាងឆាប់រហ័ស កំណើនប្រាក់ចំណូល និងកំណើនតម្រូវការប្រើប្រាស់ជាដើម (Sour, 2017; Singh et al., 2018)។

## ការរៀបចំគំនិតផ្តួចផ្តើមថ្មី

តាមរយៈអនុស្សរណៈនៃការយោគយល់រវាង អង្គការមូលនិធិអាស៊ី និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ក្នុងឆ្នាំ២០១៨ អង្គការមូលនិធិអាស៊ី បានសហការជាមួយនឹង ក.ជ.អ.ច. ដើម្បីធ្វើការសិក្សាស៊ីជម្រៅមួយលើដំណើរការគ្រប់គ្រងសំណល់រឹងនាពេលបច្ចុប្បន្នក្នុងខេត្តកែប ពិសេសក្រុងកែប ដែលជាទីក្រុងមួយជួបប្រទះបញ្ហាប្រឈមដូចគ្នានឹងទីក្រុងគោលដៅ (Secondary City) ផ្សេងទៀតនៅកម្ពុជា។ គំនិតផ្តួចផ្តើមរួមគ្នានេះ មានគោលបំណងបង្ហាញឱ្យឃើញច្បាស់ពីទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹងនាពេលបច្ចុប្បន្នក្នុងខេត្តកែប ដោយប្រើប្រាស់ព័ត៌មានដែលបានពីការជួបពិភាក្សាជាមួយអ្នកពាក់ព័ន្ធជាច្រើន ដូចជាមន្ត្រីរដ្ឋាភិបាល ប្រជាពលរដ្ឋមូលដ្ឋាន និងតំណាងវិស័យឯកជន។ ផ្អែកលើការសិក្សា សកម្មភាពសាកល្បងជាច្រើន រួមជាមួយនឹងអនុសាសន៍គោលនយោបាយ ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមជាក់លាក់របស់ខេត្ត ជាមួយនឹងការរំពឹងទុកថា វិធីសាស្ត្រនេះ អាចត្រូវបានយកទៅប្រើប្រាស់ជាគំរូសម្រាប់អនុវត្តន៍នៅតាមតំបន់ផ្សេងទៀតទូទាំងប្រទេស។ ឯកសារគោលនយោបាយសង្ខេបនេះ រៀបរាប់អំពីបរិបទ វិធីសាស្ត្រ និងរបកគំហើញនៃការសិក្សានេះដោយមានផ្តល់ជាការវិភាគអំពីបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងទីប្រជុំជន និងដំណោះស្រាយ។

របាយការណ៍សិក្សាវិសាលភាពស្តីពី **ការគ្រប់គ្រងសំណល់រឹងនៅក្នុងខេត្តកែប** អាចរកបានតាមរយៈគេហទំព័រ៖

*www.asiafoundation.org*

# វិធីសាស្ត្រ

វិធីសាស្ត្រសិក្សា រួមមានការប្រមូលព័ត៌មាន និងទិន្នន័យអំពីសំណល់ពីប្រភពជាច្រើន គួបផ្សំនឹងការផ្តល់យោបល់ពីក្រុមអ្នកជំនាញ ដែលបានមើលឃើញផ្ទាល់ ពីដំណើរការនៃការគ្រប់គ្រងសំណល់រឹងនៅខេត្តកែប។ វិធីសាស្ត្រនៃការសិក្សាមានដូចជា៖

- **ការសិក្សាឯកសារពាក់ព័ន្ធ** ត្រូវបានធ្វើឡើង ដើម្បីប្រមូល និងចងក្រងទិន្នន័យដែលមានស្រាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ ដើម្បីបង្ហាញពីទិដ្ឋភាពរួមអំពីផ្នែកសំខាន់ៗនៃការគ្រប់គ្រងសំណល់នាពេលបច្ចុប្បន្ននៅក្នុងខេត្តកែប ដូចជា៖ ការប្រមូល ការដឹកជញ្ជូន ការសម្អាត និងការចោលសំរាមជាដើម។
- **ការចុះប្រមូលព័ត៌មានផ្ទាល់នៅទីវាល** រួមបញ្ចូលការពិភាក្សាអំពីបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងសំណល់រឹងជាមួយអាជ្ញាធរថ្នាក់ស្រុក/ក្រុង រួមទាំងសហគមន៍ និងអ្នកផ្តល់សេវាកម្មប្រមូលសំរាម។
- **របាយការណ៍សិក្សាវិសាលភាព** ធ្វើការសង្ខេបពីការវិភាគ និងសេចក្តីសន្និដ្ឋានបន្ថែមពីលើការបង្ហាញពីសំណើសកម្មភាពសាកល្បង និងឱកាសធ្វើកំណែទម្រង់គោលនយោបាយ។

តំណាងមកពី ក.ជ.អ.ច. និងទីប្រឹក្សារបស់អង្គការមូលនិធិអាស៊ី រួមនឹងតំណាងមកពីលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួងបរិស្ថាន បានចូលរួមបង្កើតជាក្រុមស្រាវជ្រាវមួយសម្រាប់ការសិក្សានេះ។ បញ្ហាប្រឈមមួយដែលនាំឱ្យមានការពិបាកក្នុងការស្វែងយល់ពីការគ្រប់គ្រងសំណល់រឹងនៅខេត្តកែប គឺការខ្វះទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការ និងការគ្រប់គ្រង ដែលនេះ ក៏ជាបញ្ហាដែលកើតមានចំពោះការគ្រប់គ្រងសំណល់នៅក្នុងក្រុងដទៃទៀតនៅទូទាំងប្រទេសកម្ពុជាផងដែរ។ នៅពេលខ្វះទិន្នន័យបែបនេះ ក្រុមការងារ បានប្រើប្រាស់ទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ក្នុងទីក្រុងដែលមានបរិបទស្រដៀងគ្នាផ្សេងទៀត ដើម្បីសម្រួលដល់ការយល់ដឹងបន្ថែម។ ផ្អែកតាមការយល់ដឹងយ៉ាងរឹងមាំបែបនេះ ក្រុមការងារ បានបង្កើតក្របខ័ណ្ឌសម្រាប់ធ្វើការវិភាគ និងចំណុចចាប់ផ្តើមសម្រាប់ការរៀបចំសកម្មភាពសាកល្បងផ្តោតចំគោលដៅជាច្រើន ដើម្បីសម្រួលដល់ការរៀបចំគោលនយោបាយស្តីអំពីការគ្រប់គ្រងសំណល់រឹង ដែលកាន់តែអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង។

## លទ្ធផលនៃការសិក្សា

### ការគ្រប់គ្រងសំណល់រឹងនៅក្នុងខេត្តកែប

វិស័យទេសចរណ៍ ដើរតួនាទីយ៉ាងសំខាន់ក្នុងកំណើនសេដ្ឋកិច្ចរបស់ខេត្តកែប។ការរួមចំណែករបស់វិស័យនេះទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសលើផលប៉ះពាល់នៃការបង្កើតសំរាមដោយភ្ញៀវទេសចរ និងផលប៉ះពាល់នៃការគ្រប់គ្រងសំរាមមិនត្រឹមត្រូវ ទៅលើការយល់ឃើញអំពីខេត្តកែបដែលជាទិសដៅទេសចរណ៍។ សកម្មភាពពាណិជ្ជកម្មក្នុងវិស័យទេសចរណ៍ គឺជាប្រភពសំរាមចម្បងនៅក្នុងខេត្តកែប។ ប្រភពចម្បងបន្ទាប់ គឺជាសកម្មភាពក្នុងផ្សារ ០១ ក្នុងចំណោមផ្សារទាំង ០៤ នៅក្នុងក្រុងកែប។

លទ្ធផលសំខាន់ៗនៃការសិក្សា មានដូចជា៖

- អត្រានៃការបង្កើតសំរាម មានការកើនឡើងពី ៤៥ តោន ដល់ ៥១ តោន ក្នុងមួយថ្ងៃក្នុងឆ្នាំ ២០១៨។
- ក្នុងចំណោមសំណល់ទាំងអស់ដែលយកទៅចាក់នៅកន្លែងចាក់សំរាម សំណល់សរីរាង្គ មានរហូតដល់ ៧០%។
- ការប្រមូលសំរាមមិនបានពេញលេញ និងមិនទៀងទាត់ ជាពិសេសនៅក្នុងតំបន់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋ។
- ប្រតិបត្តិការប្រមូល និងយកសំរាមទៅចោល ពុំមានធនធានគ្រប់គ្រាន់។
- ការទាញយកសំរាមស្ងួតដូចជា ប្លាស្ទិក និងលោហៈធាតុ ដែលអាចកែច្នៃឡើងវិញ នៅមានកម្រិតទាប ដែលធ្វើឱ្យសំរាមស្ងួតទាំងនេះ ត្រូវបានយកទៅចោលនៅទីលានចាក់សំរាម (Landfill) ស្ទើរតែទាំងស្រុង។
- ស្ត្រី និងកម្មករប្រមូលសំរាមក្នុងវិស័យក្រៅប្រព័ន្ធ រួមចំណែកក្នុងការគ្រប់គ្រងសំណល់រឹងជារួម ជាពិសេសការកែច្នៃឡើងវិញ។
- សំណល់នៅតាមសមុទ្រ មានបរិមាណច្រើន ដែលភាគច្រើនជាសំរាមប្លាស្ទិកនៅតាមឆ្នេរសមុទ្រ។
- ការដុតសំរាមនៅទីវាល និងការចោលសំរាមខុសច្បាប់ មានកម្រិតខ្ពស់ដែលជាកត្តារួមចំណែកបង្កផលប៉ះពាល់អវិជ្ជមានលើខ្យល់ ទឹក និងដី។

| ទិន្នន័យអំពីប្រជាសាស្ត្រ និងទេសចរណ៍របស់ខេត្តកែប | |
|---|---|
| ចំនួនឃុំ/សង្កាត់ | ០៥ |
| ចំនួនប្រជាជន | ៤០.៤៧០ (៥.៦៧១ នាក់ក្នុងទីប្រជុំជន) (UNDP 2019)[១] |
| ចំនួនគ្រួសារក្នុងខេត្ត | ៨.៩១៧ |
| ភោជនីយដ្ឋាន សណ្ឋាគារ និងកន្លែងកម្សាន្តដទៃទៀត | សណ្ឋាគារ ១២ កន្លែង ផ្ទះសំណាក់ ៥៧ កន្លែង បឹងហ្គាឡូ ២២ កន្លែង កន្លែងកម្សាន្តផ្សេងទៀត ៥៩ កន្លែង និងភោជនីយដ្ឋាន ៣០ កន្លែង (PDoT 2019)[២] |
| ចំនួនភ្ញៀវទេសចរ | ១.៦៧៦.៥០៩[៣] |
| **ព័ត៌មានសំខាន់ៗអំពីការគ្រប់គ្រងសំណល់រឹងក្នុងក្រុងកែប** | |
| បរិមាណសំរាមក្នុងមួយថ្ងៃ (ជាមធ្យម) | ៤៥ ទៅ ៥១ តោនត្រូវបានបង្កើត (PDoE 2018)[៤] ក្នុងនោះ ២៥ តោន ត្រូវបានចោលនៅទីលានចាក់សំរាម[៥] |
| បរិមាណសំរាមក្នុងមួយថ្ងៃ (ក្នុងរដូវដែលមានភ្ញៀវទេសចរច្រើន) | ៥៥ តោន[៦] |
| អ្នកផ្តល់សេវាប្រមូលសំរាម | ប៉ុង សុឃីម (ចាប់ផ្តើមប្រតិបត្តិការ ឆ្នាំ២០១៥) |
| ការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ | មាន |

១ United Nations Development Programme - កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ
២ Provincial Department of Tourism - មន្ទីរទេសចរណ៍
៣ កិច្ចប្រជុំជាមួយអាជ្ញាធរខេត្ត ខែមេសា ឆ្នាំ២០១៩
៤ Provincial Department of Environment- មន្ទីរបរិស្ថាន
៥ កិច្ចប្រជុំជាមួយប្រតិបត្តិករប្រមូលសំរាម ខែ មេសា ឆ្នាំ ២០១៩
៦ កិច្ចប្រជុំពិគ្រោះយោបល់នៅខេត្តកែប ខែ ឧសភា ឆ្នាំ ២០១៩

| | |
|---|---|
| ខ្សែបណ្ដោយគណនេយ្យភាពរបស់អ្នកផ្ដល់សេវា | • ចុះកិច្ចសន្យាជាមួយអាជ្ញាធរក្រុង<br>• ចុះកិច្ចសន្យាជាមួយអាជ្ញាធរខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត |
| បុគ្គលិករបស់អ្នកផ្ដល់សេវា | កម្មករ ២៩ នាក់ អ្នកប្រមូលសំរាមចំនួន ២ នាក់ អ្នកចាត់ការទូទៅចំនួន ១ នាក់ |
| អត្រាគ្របដណ្ដប់នៃសេវា | ៥០% |
| ការប្រមូលថ្លៃសេវាប្រចាំខែ | ២,៤៥$ ( ផ្ទះតូច ) - ៣០$ ( សណ្ឋាគារធំៗ ) |
| ទីលានចាក់សំរាម | ភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប |
| ចម្ងាយទៅទីលានចាក់សំរាម | ១១,៥ គីឡូម៉ែត្រពីទីរួមក្រុង |

តារាងទី ១៖ ទិន្នន័យអំពីប្រជាសាស្ត្រ ទេសចរណ៍ និងសំណល់រឹងរបស់ខេត្តកែប

## បញ្ហាប្រឈមផ្នែកអភិបាលកិច្ចចំពោះកំណែទម្រង់ការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែប

ប្រព័ន្ធគ្រប់គ្រងសំណល់នៅទូទាំងសាកលលោក ជួបប្រទះបញ្ហាប្រឈមក្នុងការធានាឱ្យបាននូវអភិបាលកិច្ចល្អ។ អភិបាលកិច្ចប្រព័ន្ធគ្រប់គ្រងសំណល់ល្អ គឺជាក្របខ័ណ្ឌច្បាស់លាស់មួយដោយមានសមាសភាគសំខាន់ៗដែលនាំមកនូវការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាព។ សមាសភាគជាមូលដ្ឋាននៃអភិបាលកិច្ចប្រព័ន្ធគ្រប់គ្រងសំណល់ល្អ រួមមាន ការរៀបចំផែនការប្រតិបត្តិ និងផែនការវិនិយោគ ( ETAGIW Consortium, 2012; Hansen et al., 2002 ) ការគ្រប់គ្រង និងការត្រួតពិនិត្យហិរញ្ញវត្ថុ ( Lohri et al., 2014; Yoshino et al., 2018 ) ការគ្រប់គ្រងបរិស្ថាន និងការអនុលោមតាមលិខិតបទដ្ឋានគតិយុត្តនានា ( Dri et al., 2018; SALGA & Department of Environmental Affairs of Republic of South Africa, 2015 ) និងការពិនិត្យតាមដាន និងវាយតម្លៃលើការគ្រប់គ្រងប្រព័ន្ធ និងប្រតិបត្តិការ ( Olukanni et al., 2019 )។

កម្ពុជាបាន និងកំពុងធ្វើវិមជ្ឈការការគ្រប់គ្រងសំរាម សំណល់រឹង។ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការធ្វើវិមជ្ឈការការងារត្រួតពិនិត្យការគ្រប់គ្រងសំណល់នេះ គឺមាន អនុក្រឹត្យលេខ ១១៣ ស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ( ២០១៥ ) និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សម្រាប់គាំទ្រដល់ការពង្រឹងការអនុវត្តអនុក្រឹត្យ។ ជាមួយនឹងការអនុម័តអនុក្រឹត្យលេខ ១១៣ អំណាចគ្រប់គ្រងសំណល់ទាំងអស់ ត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរថ្នាក់ស្រុក/ក្រុង។

ការធ្វើវិមជ្ឈការនេះ ហាក់ធ្វើឱ្យមានភាពស្មុគស្មាញថែមមួយកម្រិតទៀតដល់កិច្ចខិតខំប្រឹងប្រែងក្នុងការធានាតុល្យភាពនៃអភិបាលកិច្ចសេវាគ្រប់គ្រងសំណល់រឹង"ក្នុង"ក្រុងកែប។ តាមរយៈវិមជ្ឈការ អាជ្ញាធរក្រុង គឺជាអ្នកដែលមានការទទួលខុសត្រូវចម្បងលើការគ្រប់គ្រងសំណល់រឹងទីប្រជុំជនប៉ុន្តែជាក់ពិតជាក់ស្ដែង ទាំងអាជ្ញាធរក្រុង និងអាជ្ញាធរខេត្តកែប ជាអ្នកអនុវត្តការងារនេះ ដោយអាជ្ញាធរទាំងពីរថ្នាក់ បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមមួយក្នុងក្រុងកែប។ នេះ គឺជាបញ្ហានៃភាពមិនអនុលោមតាមស្មារតីអនុក្រឹត្យ ១១៣ ទាក់ទងជាមួយការរៀបចំកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាម។

បញ្ហាប្រឈមផ្សេងទៀត មានដូចជា ភាពមានកម្រិតនៃការពិនិត្យតាមដាន និងវាយតម្លៃរបស់រដ្ឋបាលខេត្ត និងក្រុងលើការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុនប្រមូលសំរាម ភាពមានកម្រិតនៃការសម្របសម្រួលការពិនិត្យ តាមដាន និងវាយតម្លៃរវាងក្រសួងសំខាន់ៗ (ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) លើការអនុវត្តការងារគ្រប់គ្រងសំណល់រឹងនៅថ្នាក់ក្រោមជាតិ និងបញ្ហាកង្វះទិន្នន័យស្ដីពីស្ថានភាពបច្ចុប្បន្ននៃការរៀបចំកិច្ចសន្យាលើការប្រមូលសំរាមទាំងនៅថ្នាក់ខេត្ត និងក្រុង។

ការផ្ដល់ថវិកាពុំបានគ្រប់គ្រាន់ដល់វិស័យនេះ ក៏ជាកត្តាដ៏សំខាន់មួយផងដែរ។ ប្រព័ន្ធដែលពុំមានធនធានគ្រប់គ្រាន់ គួបផ្សំនឹងប្រតិបត្តិករវិស័យឯកជន ប្រើប្រាស់គំរូអាជីវកម្មដែលពឹងអាស្រ័យលើការប្រមូលថ្លៃសេវាតែមួយគត់ ជាហេតុនាំឱ្យសេវាប្រមូលសំរាមផ្ដោតតែលើទីតាំងបង្កើតសំរាមធំៗ ដែលហ៊ានបង់ថ្លៃសេវាខ្ពស់ខ្ពស់ ធ្វើឱ្យសេវាប្រមូលសំរាមនៅមានការខ្វះខាតយ៉ាងច្រើន និងនាំឱ្យមានការសម្រេចលទ្ធផលមិនសូវជាទីពេញចិត្តសម្រាប់សហគមន៍ទាំងមូល។

# ប្រធានបទជាអាទិភាពសម្រាប់កែលំអការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែប

លទ្ធផលដែលបានរកឃើញខាងលើបង្ហាញអំពីចំណុចអាទិភាពសំខាន់ៗសម្រាប់កែលំអដែលមានដូចជា៖

- **ការប្រមូលសំរាម**–ការប្រមូលសំរាមនៅកម្ពុជាគ្របដណ្តប់លើបរិមាណសំរាមតិចតួច (Sour, 2017)។ នេះ អាចដោយសារកត្តាជាច្រើន ដូចជា ការទទួលបានសេវាប្រមូលសំរាមនៅមានកម្រិត ការបន្តនូវការប្រើប្រាស់វិធីសាស្ត្រចោលសំរាមបែបប្រពៃណី ដូចជា ការដុតសំរាមចោលជាដើម ឬការខ្វះការយល់ដឹង ឬការយកចិត្តទុកដាក់ចំពោះផលប៉ះពាល់ពីការចោលសំរាមខុសច្បាប់មកលើបរិស្ថាន។ ចំណុចនេះ អាចបង្កផលប៉ះពាល់អវិជ្ជមានមកលើសុខភាពដោយសារការថមថយនូវគុណភាពខ្យល់ ការប្រឈមនឹងពពួកសត្វដែលចូលចិត្តកកាយសំរាម និងការបំពុលទឹកសម្រាប់ប្រើប្រាស់ និងការកាត់បន្ថយគុណភាពដីដែលមានទីតាំងនៅជិតកន្លែងចោលសំរាម (Engel et al., 2016)។
- **សំរាមនៅតាមសមុទ្រ**–សំរាមដែលកើតចេញពីការប្រមូលសំរាមនៅមានកម្រិតទាប និងការចោលពុំបានត្រឹមត្រូវ នាំឱ្យមានសំរាមហូរចូលទៅក្នុងសមុទ្រ ដែលសំរាមទាំងនេះភាគច្រើនជាសំរាមស្រាលៗ ដូចជាប្លាស្ទិកដែលហូរតាមស្ទឹង និងទន្លេទៅកាន់សមុទ្រដែលនាំឱ្យមានការកើនឡើងនូវសំរាមតាមឆ្នេរសមុទ្រ និងនៅក្នុងសមុទ្រ (Marine Litter Solutions, 2019)។ នៅមានផលប៉ះពាល់ផ្សេងទៀតដែលគេពុំទាន់បានសិក្សា ស្វែងយល់ឱ្យបានច្រើននៅឡើយពាក់ព័ន្ធនឹងផលប៉ះពាល់ដែលប្លាស្ទិកនៅតាមសមុទ្រមានលើមច្ឆជាតិ និងជីវចម្រុះក្នុងសមុទ្រផ្សេងទៀត និងបង្កការគំរាមកំហែងដល់ការរស់នៅរបស់ជីវចម្រុះទាំងនោះ ព្រមទាំងឧស្សាហកម្មនេសាទ (Barboza et al., 2018) ជាដើម។
- **សំណល់សរីរាង្គ** – សំណល់សរីរាង្គ មានភាគរយខ្ពស់ ក្នុងចំណោមសំណល់រឹងទីក្រុង ដែលត្រូវបានបង្កើតឡើងនៅក្នុងខេត្តកែប ហើយក៏ជាចំណុចចាប់ផ្តើមដ៏ល្អមួយ សម្រាប់ការពិចារណាពីឱកាសធ្វើប្រព្រឹត្តិកម្មលើសំណល់ទាំងនេះ (Sang-Arun et al., 2011)។ ព្រឹត្តិកម្មសំណល់សរីរាង្គអាចត្រូវបានធ្វើឡើងតាមវិធីច្រើនបែបច្រើនយ៉ាង។ ការកែច្នៃប្រើប្រាស់សំណល់បែបនេះធ្វើជាជីកំប៉ុស្ត គឺជាបច្ចេកទេសងាយស្រួល និងចំណាយតិច ដែលត្រូវបានប្រើប្រាស់ភាគច្រើនក្នុងបរិបទនៃសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ ប៉ុន្តែ ជារឿយៗសំណល់សរីរាង្គ បញ្ចេញក្លិន និងជាប្រភពនៃឧស្ម័នមេតានហើយបង្កហានិភ័យដ៏ធំចំពោះសុខភាពមនុស្ស និងបរិស្ថានដូចជា ការបំពុលទឹក និងបំពុលដីជាដើម (Ferronato et al., 2019) ដែលគួរត្រូវបានយកទៅពិចារណា។
- **ការកែច្នៃឡើងវិញ** – សំរាមស្ងួតដែលអាចកែច្នៃឡើងវិញ ដូចជា ដបប្លាស្ទិក លោហៈធាតុ ក្រដាស កាតុង ក្រដាស គឺជាសំរាមដែលបរិមាណបន្តកើនឡើងនៅក្នុងខេត្តកែប ហើយក៏ជាប្រភេទសំរាមដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងពិចារណាពីឱកាសវិនិយោគនាពេលអនាគត។ ការទាញយកសំរាមស្ងួតដែលអាចកែច្នៃឡើងវិញយកមកប្រើប្រាស់ជាជម្រើសមួយ និងជួយដល់ការដកហូតធនធានដែលមានតម្លៃ ដើម្បីយកមកប្រើប្រាស់ឡើងវិញក្នុងខ្សែសង្វាក់តម្លៃនៃផលិតកម្មផ្សេងទៀត និងជួយបង្កើនប្រាក់ចំណូលដល់អ្នកប្រមូលសំរាម កាត់បន្ថយបរិមាណសំរាម កាត់បន្ថយតម្រូវការទំហំដីទីលានសម្រាប់ចាក់សំរាម និងបង្វែរសំរាមចេញពីទីលានចាក់សំរាម ការដុតសំរាម និងការចោលសំរាម។
- **ការគ្រប់គ្រងសំណល់បែបវិមជ្ឈការ** – ការដាក់ចេញនូវដំណោះស្រាយជាក់ស្តែងដើម្បីដោះស្រាយបញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់រឹងនៅក្នុងខេត្តកែប ទាមទារឱ្យមានការប្រើប្រាស់វិធីសាស្ត្រមួយ ដោយធ្វើការពិចារណាពីលើបញ្ហាប្រឈមនានា ដែលប្រព័ន្ធបច្ចុប្បន្នកំពុងជួបប្រទះ ដូចជាធនធានហិរញ្ញវត្ថុ និងកម្មករជំនាញនៅមានចំនួនកំណត់ជាដើម។ ការធ្វើប្រព្រឹត្តិកម្មសំណល់រឹងទីក្រុងបែបវិមជ្ឈការ ផ្តល់ឱ្យសហគមន៍តូចៗដូចជា ខេត្តកែបជាដើម នូវគំរូវិនិយោគតម្លៃទាប និងផ្តល់ឱកាសឱ្យគេអាចធ្វើសមាហរណកម្មកម្មករក្នុងវិស័យប្រមូលសំរាមទាំងផ្លូវការ និងក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធទាំងនេះ។ ការធ្វើបែបនេះ អាចផ្តល់ឱកាសឱ្យអ្នកប្រមូលសំរាម រកចំណូលបន្ថែម និងជួយសន្សំសំចៃចំណាយរបស់រដ្ឋាភិបាលផងដែរ។
- **ប្រតិបត្តិការនៅកន្លែងចោលសំរាម** – ទីលានចោលសំរាមបច្ចុប្បន្ននៅក្នុងខេត្តកែប ទាមទារឱ្យមានការកែលំអបន្ថែម ដើម្បីបញ្ចូលការការពារបរិស្ថានដូចជាដី និងទឹកជាដើម។

# ទស្សនទានសាកល្បង

ទស្សនទានសាកល្បងចំនួន ០៥ តំណាងឱ្យគោលវិធីបែប គ្រប់ជ្រុងជ្រោយ ត្រូវបានតាក់តែងឡើង ដើម្បីឆ្លើយតបចំពោះ សមាសធាតុសារវន្តដែលចាំបាច់ ដើម្បីជំរុញឱ្យខេត្តកែប ឈានឆ្ពោះទៅរកដំណោះស្រាយការគ្រប់គ្រងសំណល់រឹង ប្រកបដោយប្រសិទ្ធភាព។ ទស្សនទានទាំង ០៥ ដែលត្រូវ បានស្នើឡើងរួមមាន៖

១. **អភិបាលកិច្ច** - ការស្នើឡើងនូវទស្សនទាននេះ គឺដើម្បី ឆ្លើយតបចំពោះបញ្ហាប្រឈមដែលកើតឡើងដោយសារ ដំណើរការធ្វើវិមជ្ឈការមិនពេញលេញ ក្នុងនោះគឺភាពត្រួត គ្នានៃសមត្ថកិច្ចគ្រប់គ្រង និងការត្រួតពិនិត្យរបស់អាជ្ញាធរ ដែលអាចនាំឱ្យប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹង នៅមានកម្រិត។ ទស្សនទានសាកល្បងនេះ នឹងបញ្ចូល ការផ្តោតការយកចិត្តទុកដាក់លើការពិនិត្យតាមដាន និង វាយតម្លៃ ដើម្បីឱ្យការគ្រប់គ្រង និងប្រតិបត្តិការកាន់តែ មានភាពល្អប្រសើរជាងមុន។

២. **បច្ចេកវិទ្យា និងប្រព័ន្ធបែបវិមជ្ឈការ** - ការលើកឡើងនូវ ទស្សនទាននេះ គឺផ្អែកតាមទ្រឹស្តីស្តីពីការគ្រប់គ្រងសំណល់ ដែលជំរុញឱ្យមានការធ្វើប្រព្រឹត្តិកម្មសំណល់ក្នុងទ្រង់ទ្រាយ តូច ប្រើប្រាស់បច្ចេកវិទ្យាកម្រិតទាប និងចំណាយតិច នៅ កៀកនឹងប្រភពដែលបង្កើតសំណល់ ដែលអាចឱ្យគេយក ទៅប្រើប្រាស់បែបវិមជ្ឈការនៅកម្រិតសហគមន៍ ឬនៅ ថ្នាក់ស្រុក។

៣. **សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលាន ចាក់សំរាម** - ទស្សនទាននេះ ផ្តោតលើកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រីកសេវាប្រមូលសំរាមតាមរយៈការកំណត់រកតំបន់ ដែលមិនទាន់ទទួលបានសេវាប្រមូលសំរាម ឬតំបន់ដែល មិនទាន់ទទួលបានសេវាពេញលេញ និងដើម្បីកែលំអ ទីលានចាក់សំរាមរបស់ខេត្តកែបតាមរយៈការអនុវត្តវិធានការ ការពារបរិស្ថាន។

៤. **តួនាទីនៃវិស័យក្រៅប្រព័ន្ធ** – ទស្សនទាននេះ សំដៅលើការ ផ្តួចផ្តើមឱ្យមានការសន្ទនារវាងអាជ្ញាធរក្រុង និងកម្មករ ប្រមូលសំរាមក្នុងវិស័យក្រៅប្រព័ន្ធ។ តាមរយៈកិច្ចពិភាក្សា និងកិច្ចព្រមព្រៀង អាជ្ញាធរក្រុង អាចគាំទ្រដល់កម្មករប្រមូល សំរាមក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងការធ្វើការងារឆ្ពោះទៅរក ដំណោះស្រាយ ដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ ទាំងមូល ក្នុងនោះរួមទាំងភាពល្អប្រសើរជាងមុននៃការញែក និងការទាញយកធនធានដែលអាចកែច្នៃឡើងវិញបាន។

៥. **ការអប់រំ និងការយល់ដឹង** - ទស្សនទាននេះ គឺជាការរៀបចំ យុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈឱ្យស្របតាម បរិបទរបស់កម្ពុជា ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធ នៅគ្រប់កម្រិត និងគ្រប់ផ្នែកនៃសង្គមកម្ពុជា។ យុទ្ធនាការ នេះ នឹងផ្តោតលើសារអប់រំផ្សព្វផ្សាយអំពីប្រធានបទដែល ឆ្លុះបញ្ចាំងពីគុណតម្លៃប្រវត្តិសាស្ត្រ និងវប្បធម៌ក្នុងមូលដ្ឋាន និងផ្សារភ្ជាប់ជាមួយនឹងការគ្រប់គ្រងសំណល់រឹងផងដែរ។

| ចំណុចដែលត្រូវផ្តោតក្នុងការសាកល្បង | ទិដ្ឋភាព | អ្នកចូលរួម | គោលបំណង | កត្តាហិរញ្ញវត្ថុ/សេដ្ឋកិច្ច | ធនធានដែលចាំបាច់ |
|---|---|---|---|---|---|
| **១. អភិបាលកិច្ច** | - ការគ្រប់គ្រងសំណល់រឹងនាពេលបច្ចុប្បន្ននេះ ពុំបានឆ្លើយតបចំពោះចក្ខុវិស័យដែលត្រូវបានដាក់ចេញក្នុងអនុក្រឹត្យលេខ ១១៣ ប្រកាសលេខ ០៧៣ ស្តីពីការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៀតឡើយ។<br>- ការគាំទ្រ និងការពិនិត្យតាមដាន និងវាយតម្លៃពីថ្នាក់ជាតិ នៅមានកម្រិត | - អាជ្ញាធរស្រុក/ក្រុង ខេត្ត (រាប់បញ្ចូលទាំងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ទីរបរិស្ថាន ផងដែរ)<br>- រដ្ឋាភិបាលនៅថ្នាក់ជាតិ (តាមរយៈក្រុមការងារបច្ចេកទេស) | - ការត្រួតពិនិត្យច្បាស់លាស់លើការអនុវត្តការគ្រប់គ្រងសំណល់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តនានា<br>- ការសម្របសម្រួល និងការត្រួតពិនិត្យក្នុងលក្ខណៈជាប្រព័ន្ធជាងមុនពីថ្នាក់ជាតិ | **ការចំណាយ៖** ចំណាយរយៈពេលខ្លី ដើម្បីធ្វើឱ្យប្រព័ន្ធមានភាពអនុលោម<br>**អត្ថប្រយោជន៍៖**ទទួលបានប្រសិទ្ធភាពរយៈពេលមធ្យម និងរយៈពេលវែង | - អ្នកចូលរួមដែលត្រូវបានចាត់តាំងពីអាជ្ញាធរនីមួយៗ<br>- ជំនួយបច្ចេកទេស ដើម្បីគាំទ្រដល់អន្តរកាល<br>- យន្តការ/ទំនាក់ទំនងផ្លូវការ រវាងដៃគូអភិវឌ្ឍន៍ និងយន្តការផ្លូវការរបស់រដ្ឋ (ឧទាហរណ៍ក្រុមការងារបច្ចេកទេសជាដើម) |
| **២. បច្ចេកវិទ្យា និងប្រព័ន្ធបែបវិមជ្ឈការ** | ការផ្ទេរធនធានដោយផ្ទាល់ និងការផ្តល់ចំណេះដឹងដល់តំបន់លំនៅដ្ឋាន ដែលពុំទាន់ទទួលសេវាគ្រប់គ្រាន់ និងដែលមានអត្រាប្រមូលសំរាមទាប | អាជ្ញាធរស្រុក/ក្រុង ខេត្ត និងប្រតិបត្តិករវិស័យឯកជន | អនុវត្តសកម្មភាពគ្រប់គ្រងសំណល់តាមសហគមន៍ក្នុងទ្រង់ទ្រាយតូច | **ការចំណាយ៖**<br>ការចំណាយលើសំភារៈ និងចំណាយលើការបណ្តុះបណ្តាល ដើម្បីអនុវត្តប្រព័ន្ធ<br>**អត្ថប្រយោជន៍៖** ជម្រើសដែលអស់ចំណាយទាបជំនួសឱ្យប្រព័ន្ធបែបមជ្ឈការ | - តំបនសម្រាប់អនុវត្តសាកល្បង<br>- ការផ្តល់ជំនួយបច្ចេកទេស សម្រាប់ធ្វើការវិភាគ/សិក្សាពីសមិទ្ធិលទ្ធភាព<br>-ធនធានសម្រាប់អនុវត្តសាកល្បង |
| **៣. សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម** | ធ្វើការកែសម្រួលកិច្ចសន្យាផ្តល់សេវាប្រមូលសំរាមនាពេលបច្ចុប្បន្ន ដោយធ្វើការពិចារណាពីមេរៀនដែលទទួលបាន | អាជ្ញាធរស្រុក/ក្រុង ខេត្ត និងប្រតិបត្តិករវិស័យឯកជន | រៀបចំវិធីសាស្រ្តសាកល្បងដើម្បីដោះស្រាយបញ្ហាសេវាប្រមូលសំរាមដែលមិនមានការគ្របដណ្តប់ពេញលេញ និងបញ្ហាទីលានចាក់សំរាម និងផ្តោតលើឱកាសកែលំអដែលងាយស្រួលក្នុងការអនុវត្ត | **ការចំណាយ៖** ចំណាយលើការអនុវត្តការពង្រីកសេវា និងការកែលំអទីតាំង<br>**អត្ថប្រយោជន៍៖** ការបន្ថយការចំណាយលើបរិស្ថាន និងសុខភាពសម្រាប់អាជ្ញាធរ និងប្រជាពលរដ្ឋ | - តំបនសម្រាប់អនុវត្តសាកល្បង<br>- ការផ្តល់ជំនួយបច្ចេកទេស សម្រាប់ធ្វើការវិភាគ/សិក្សាពីសមិទ្ធិលទ្ធភាព<br>- ធនធានសម្រាប់អនុវត្តសាកល្បង |

| ចំណុចដែលត្រូវផ្តោតក្នុងការសាកល្បង | ទិដ្ឋភាព | អ្នកចូលរួម | គោលបំណង | កត្តាហិរញ្ញវត្ថុ/សេដ្ឋកិច្ច | ធនធានដែលចាំបាច់ |
|---|---|---|---|---|---|
| **៤. តួនាទីនៃវិស័យក្រៅប្រព័ន្ធ** | គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ អភិបាលកិច្ចក្នុងវិស័យនេះ ធ្វើការពិចារណាតិចតួចប៉ុណ្ណោះលើផលប៉ះពាល់សង្គម ដែលបង្កឡើងដោយសារការគ្រប់គ្រងសំណល់ | អាជ្ញាធរថ្នាក់ស្រុក/ក្រុង ខេត្ត និងថ្នាក់ជាតិ អង្គការ/ស្ថាប័នដែលជួយសម្របសម្រួល និងវិស័យក្រៅប្រព័ន្ធ | រៀបចំវេទិកា ដើម្បីឱ្យមានការពិគ្រោះយោបល់ស្តីពីគំរូសហការរវាងវិស័យផ្លូវការ និងក្រៅប្រព័ន្ធ | **ការចំណាយ៖** ចំណាយលើការចាប់ផ្តើមអនុវត្តវិធីសាស្ត្របែបកម្មវិធីដើម្បីជំរុញឱ្យមានការចូលរួមពីវិស័យក្រៅប្រព័ន្ធ<br>**អត្ថប្រយោជន៍៖** ឱកាសមួយចំនួនសម្រាប់ធ្វើការចែករំលែកប្រាក់ចំណូលដែលបានពីការទាញសម្ភារមកប្រើប្រាស់ឡើងវិញ និងការកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលមានឱកាសតិចតួច | - ការគាំទ្រពីរដ្ឋាភិបាលដើម្បីឱ្យមានការរៀបចំកិច្ចពិគ្រោះយោបល់ និងការធ្វើសកម្មភាពនានា<br>- ធនធានសម្រាប់សម្របសម្រួលកិច្ចពិគ្រោះយោបល់<br>- ការគាំទ្រពីអ្នកជំនាញអន្តរជាតិ ដែលមានបទពិសោធន៍ធ្វើការងារជាមួយនឹងវិស័យក្រៅប្រព័ន្ធ |
| **៥. ការអប់រំ និងការយល់ដឹង** | លទ្ធភាពផ្នែកថវិការបស់រដ្ឋាភិបាលនៅមានកម្រិត សម្រាប់ការអប់រំ និងការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ | អាជ្ញាធរថ្នាក់ស្រុង/ក្រុង ខេត្ត ប្រតិបត្តិករវិស័យឯកជន អង្គការពាក់ព័ន្ធដែលធ្វើការងារតាមសហគមន៍ និងអង្គការ/ស្ថាប័នដែលជួយសម្របសម្រួល | រៀបចំគំរូសម្រាប់បង្កើនការយល់ដឹងអំពីសំណល់ដល់ប្រជាពលរដ្ឋគោលដៅ | **ការចំណាយ៖** ចំណាយលើការចាប់ផ្តើមអនុវត្តវិធីសាស្ត្របែបកម្មវិធី ដើម្បីអប់រំ និងជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ<br>**អត្ថប្រយោជន៍៖** ផលដែលបានពីការវិនិយោគក្នុងរយៈពេលវែង និងរយៈពេលខ្លីលើការកែលំអឥរិយាបថរបស់ប្រជាពលរដ្ឋ | - ការគាំទ្ររបស់រដ្ឋាភិបាលដល់កិច្ចពិគ្រោះយោបល់នៅតាមសហគមន៍<br>- ធនធានសម្រាប់រៀបចំសកម្មភាព និងសម្ភារនានា |

តារាងទី ២៖ ធាតុផ្សេងៗទាំង ០៥ នៅក្នុងទស្សនទានសកម្មភាពអនុវត្តសាកល្បងដែលត្រូវបានស្នើឡើងសម្រាប់ខេត្តកែប

# អនុសាសន៍គោលនយោបាយ

អនុសាសន៍គោលនយោបាយខាងក្រោមគឺឆ្លើយតបចំពោះគោលបំណងជាច្រើនក្នុងពេលជាមួយគ្នា ប៉ុន្តែ ផ្តោតជុំវិញទស្សនទានជាមូលដ្ឋានមួយចំនួន ដូចជា ការអភិវឌ្ឍបៃតង និរន្តរភាពផ្នែកបរិស្ថាន សេដ្ឋកិច្ចចក្រា (Circular Economy) ការលើកកម្ពស់ជីវភាពរស់នៅ និងប្រសិទ្ធភាពចំណាយ។ អនុសាសន៍គោលនយោបាយសំខាន់ៗពាក់ព័ន្ធជាមួយនឹងទស្សនទានសាកល្បងនីមួយៗរួមមាន៖

១. **ពង្រឹង ការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យបរិស្ថាននិងសណ្តាប់ធ្នាប់សាធារណៈក្នុងរដ្ឋបាលក្រុងកែប៖** សកម្មភាពនេះ មានគោលបំណងពង្រឹងគណនេយ្យភាពរបស់អាជ្ញាធរក្រុង លើការគ្រប់គ្រងសំណល់នៅមូលដ្ឋានជាមួយគ្នា នឹងការផ្តល់លទ្ធភាពបង្កើនការយល់ដឹងរបស់មន្ត្រីក្រុងអំពីប្រតិបត្តិការគ្រប់គ្រងសំណល់រឹង។ សកម្មភាពនេះជាការផ្តោតផងដែរលើការធានានូវភាពជោគជ័យនៃការផ្ទេរតួនាទីត្រួតពិនិត្យសេវាគ្រប់គ្រងសំណល់ទៅឱ្យអាជ្ញាធរក្រុងកែប ជាពិសេសការិយាល័យដែលទើបបង្កើតថ្មីឱ្យមានចំនួនមន្ត្រី និងថវិកាគ្រប់គ្រាន់។
*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

២. **រៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដើម្បីគាំទ្រការធ្វើវិមជ្ឈការ និងការកែលំអប្រតិបត្តិការគ្រប់គ្រងសំណល់រឹងតាមរយៈការផ្តោតលើការគ្រប់គ្រងទិន្នន័យ៖** ដើម្បីធានាប្រសិទ្ធភាពប្រតិបត្តិការ និងដំណើរការប្រព័ន្ធឱ្យបានរឹងមាំ ចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមលើប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។ គួរមានការ ផ្តោតការយកចិត្តទុកដាក់បែបនេះលើប្រតិបត្តិការគ្រប់គ្រង ដូចជា ការបំពេញការងារផ្នែកហិរញ្ញវត្ថុ និង រដ្ឋបាលរបស់អង្គភាពគ្រប់គ្រងសំណល់ ដោយធ្វើការសម្របសម្រួលជាមួយនឹងស្ថាប័នដែលធ្វើការត្រួតពិនិត្យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាផ្សារភ្ជាប់ទំនាក់ទំនងជាមួយការពិនិត្យតាមដានប្រតិបត្តិការគ្រប់គ្រងសំណល់រឹងនៅក្នុងមូលដ្ឋានផងដែរ។ ការស្វែងយល់ឱ្យបានគ្រប់ជ្រុងជ្រោយអំពីប្រភេទសំណល់ និងបរិមាណសំណល់ មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការរៀបចំផែនការប្រតិបត្តិការ និងការវិនិយោគ ព្រមទាំងការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងសំណល់ ជាពិសេសដើម្បីកំណត់ពីរបៀបគ្រប់គ្រងប្រភេទសំណល់ផ្សេងៗគ្នា។
*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

៣. **កំណត់ពីធនធានដែលចាំបាច់ ដើម្បីសម្រេចគោលដៅនៃការគ្រប់គ្រងសំណល់រឹងទីក្រុង និងរៀបចំយុទ្ធសាស្ត្របង្កើនចំណូលដើម្បីឆ្លើយតបចំពោះតម្រូវការចាំបាច់៖** ស្របគ្នានឹងការពង្រឹងការយកចិត្តទុកដាក់លើការពិនិត្យតាមដាន និងវាយតម្លៃ អាជ្ញាធរដែលពាក់ព័ន្ធក្នុងខេត្ត និងក្រុងកែប ត្រូវធានាឱ្យមានការផ្តល់ធនធានឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការសម្រេចគោលបំណងនៃការគ្រប់គ្រងសំណល់តាមរយៈភាពដៃគូនៅមូលដ្ឋាន។ នេះតម្រូវឱ្យមានការវិភាគលើជម្រើសយន្តការផ្តល់ថវិកាគាំទ្រដល់ប្រតិបត្តិការគ្រប់គ្រងសំណល់រឹង។ នាពេលបច្ចុប្បន្នប្រតិបត្តិការនៅក្នុងខេត្តកែបពឹងអាស្រ័យលើការប្រមូលថ្លៃសេវាគ្រប់គ្រងដោយប្រតិបត្តិករវិស័យឯកជន ដែលនាំឱ្យសេវាប្រមូលសំរាមនេះ ផ្តោតការយកចិត្តទុកដាក់ភាគច្រើនលើតម្រូវការរបស់សហគ្រាសពាណិជ្ជកម្មដែលជាអ្នកបង្កើតសំរាមក្នុងទ្រង់ទ្រាយធំ។ ដើម្បីយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់លើការគ្រប់គ្រងសំណល់នៅថ្នាក់សហគមន៍ ថវិកាសម្រាប់ប្រតិបត្តិការសំណល់ ចាំបាច់ត្រូវមានការពង្រីក និងស្វែងរកបន្ថែមពីប្រភពផ្សេងៗ។
*សកម្មភាពសាកល្បងនៅក្រោម៖ អភិបាលកិច្ច*

៤. **សាកល្បងគំរូភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដែលរួមបញ្ចូលការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដើម្បីគាំទ្រការញែកសំរាម នៅប្រភពដើមផ្ទាល់ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចចក្រា៖** គម្រោងលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ត្រូវបានរកឃើញថា មានប្រសិទ្ធភាពក្នុងការបង្កើនការចូលរួមក្នុងការញែកសំណល់។ រដ្ឋបាលក្រុងកែប អាចទទួលបានលទ្ធផលនេះ តាមរយៈការអនុវត្តគំរូសាកល្បងដែលមានឈ្មោះថា ធនាគារសំណល់។ ប្រជាពលរដ្ឋ អាចទទួលបានការទូទាត់ជាសាច់ប្រាក់ពីសំរាមស្ងួត (ប្លាស្ទិកលោហៈ និងអាលុយមីញ៉ូមជាដើម) ដែលបានយកទៅដាក់នៅធនាគារ។ គំរូមួយទៀត គឺជាការដាក់បញ្ចូលកម្មករក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានស្រាប់។ ការខិតខំប្រឹងប្រែងប្រមូលសំរាមរបស់កម្មករក្នុងវិស័យក្នុង និងក្រៅប្រព័ន្ធ អាចកាត់បន្ថយបរិមាណសំរាមនៅទីលានចាក់សំរាមក្នុងខេត្តកែប ព្រមទាំងជួយគាំទ្រដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋងាយរងគ្រោះផងដែរ។ រដ្ឋបាលក្រុងកែប គួរតែបង្កើតកន្លែងប្រមូលសំរាមស្ងួតដែលអាចកែច្នៃបាន និងធ្វើការងារជាមួយនឹងវិស័យក្រៅប្រព័ន្ធ ដើម្បីបង្កើតគំរូសហការគ្នាសម្រាប់ការប្រមូល និងលក់សំណល់ ដែលអាចកែច្នៃបានទៅជាផលិតផលថ្មី

និងប្រភពនៃថាមពល។ ភាពជាដៃគូជាមួយដេប៉ូទិញ-លក់អេតចាយ និង/ឬវិស័យឯកជន គួរតែជាផ្នែកមួយនៃគំរូសាកល្បងទាំងពីរផងដែរ ដើម្បីបញ្ជូនសំណល់ទៅកាន់កន្លែងកែច្នៃសំណល់។

*សកម្មភាពសាកល្បងនៅក្រោម៖ ការអប់រំ និងការយល់ដឹង និងតួនាទីរបស់វិស័យក្រៅប្រព័ន្ធ*

៥. **បង្កើតភាពជាដៃគូ ដើម្បីសាកល្បងការផលិតជីវឧស្ម័នពីសំណល់សរីរាង្គពីផ្សារនៅខេត្តកែប តាមរយៈការបំបែកដោយគ្មាន អុកស៊ីសែន (Anaerobic Digestion) ដែលអាចបញ្ចៀសសំណល់សរីរាង្គចេញពីទីលានចាក់សំរាមចុងក្រោយ និងធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃការធ្វើជីកំប៉ុស្តនៅនឹងប្រភពសំណល់ផ្ទាល់៖** ទីផ្សារ និងកន្លែងផ្តល់សេវាអាហារ រួមទាំងកន្លែងកែច្នៃអាហារផ្សេងទៀត បង្កើតបានសំណល់សរីរាង្គក្នុងបរិមាណដ៏ច្រើន។ សំណល់សរីរាង្គអាចប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ដំណើរការឡជីវឧស្ម័ន ដែលជាដំណើរការមួយជួយកាត់បន្ថយបរិមាណសំរាមក្នុងពេលជាមួយគ្នាអាចជួយផលិតជីវឧស្ម័នបានផងដែរ។ ទីផ្សារក្នុងក្រុងកែប ផ្តល់ឱកាសសាកល្បងគំនិតផ្តួចផ្តើមនេះជាមួយនឹង កម្មវិធីឡជីវឧស្ម័នជាតិ ដើម្បីគាំទ្រដល់និរន្តរភាពក្នុងការធ្វើប្រព្រឹត្តិកម្មសំណល់រឹងក្នុងក្រុងកែប។ សំណល់សរីរាង្គ ក៏ជាឱកាសមួយទៀតសម្រាប់ធ្វើជីកំប៉ុស្តសម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម។ ក្រុងកែប គួរតែធ្វើការវាយតម្លៃសមិទ្ធិលទ្ធភាពសម្រាប់ការធ្វើជីកំប៉ុស្តនៅនឹងកន្លែងផ្ទាល់នៅក្នុងតំបន់ ដែលមិនទទួលបានការផ្តល់សេវាប្រមូលសំរាម។

*សកម្មភាពសាកល្បងនៅក្រោម៖ បច្ចេកវិទ្យា និងប្រព័ន្ធបែបវិមជ្ឈការ*

៦. **បង្កើតផែនទីបង្ហាញផ្លូវ ដើម្បីសម្រេចឱ្យបាននូវការប្រមូលសំរាមទូទាំងខេត្តកែប៖** ការពង្រីកការគ្រប់ដណ្តប់នៃការប្រមូលសំរាមឱ្យបានទាំងស្រុង មានសារៈសំខាន់ ដើម្បីឆ្លើយតបចំពោះ បញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់ដែលខេត្តកែបកំពុងជួបប្រទះ។ ការជំរុញឱ្យមានការប្រមូលសំរាមទូទាំងខេត្តបែបនេះ នឹងជួយឱ្យរដ្ឋបាល ខេត្តកែបអាចឆ្លើយតបចំពោះបញ្ហានៃការដុតសំរាមពាសវាលពាសកាល និងបញ្ហាកើនឡើងប្លាស្ទិកក្នុងសមុទ្រផងដែរ។ការកំណត់គោលដៅច្បាស់លាស់ និងជំហានដែលចាំបាច់ជាមាគ៌ាបង្ហាញផ្លូវយ៉ាងច្បាស់ ដើម្បីឈានទៅសម្រេចគោលដៅ។

*សកម្មភាពសាកល្បងនៅក្រោម៖ សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម*

៧. **រៀបចំផែនការសកម្មភាព ដើម្បីធានាឱ្យមានទីលានចាក់សំរាមត្រឹមត្រូវ និងកែលំអប្រតិបត្តិការដោយវិធីសាស្ត្រដែលចំណាយទាបដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន៖** ខេត្តកែប គួរតែផ្តោតការយកចិត្តទុកដាក់លើការកែលំអប្រតិបត្តិការនៅទីលានចាក់សំរាម។ផ្លូវចូលទៅកាន់ទីលាននេះគួរតែជួសជុល និងការប្រតិបត្តិការ គួរតែផ្លាស់ប្តូរតាមរយៈ ការកាត់បន្ថយការដុតសំរាម ការទុកដាក់សំរាមឱ្យបានសមស្រប និងការប្រើប្រាស់សម្ភារសម្រាប់គ្របសំរាមជាប្រចាំ ដើម្បីជួយកាត់បន្ថយផលប៉ះពាល់បរិស្ថាន។

*សកម្មភាពសាកល្បងនៅក្រោម៖ សេវាប្រមូលសំរាមគ្របដណ្តប់ទាំងស្រុង និងកែលំអទីលានចាក់សំរាម*

៨. **គាំទ្រដល់ការអនុវត្តគំនិតផ្តួចផ្តើមបង្កើនការយល់ដឹង ដើម្បីអប់រំប្រជាពលរដ្ឋ អំពីសារៈសំខាន់នៃការចោលសំរាមឱ្យបានត្រឹមត្រូវ ផលប៉ះពាល់ទៅលើសុខភាព និងបរិស្ថានដែលបង្កឡើងដោយសារការដុតសំរាម និងការផាកពិន័យចំពោះករណីចោលសំរាមពុំបានត្រឹមត្រូវ៖** មានតែតាមរយៈការគាំទ្រ និងការជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋានតែប៉ុណ្ណោះដែលអាចធ្វើឱ្យមានភាពជឿនលឿនពិតប្រាកដឆ្ពោះទៅរកការកែលំអការគ្រប់គ្រងសំណល់។ ការបង្ហាញពីសញ្ញាយ៉ាងរឹងមាំរបស់អ្នកដឹកនាំនៅមូលដ្ឋានគឺជាការបង្ហាញពីការប្តេជ្ញាចិត្តអនុវត្តសកម្មភាព ដើម្បីផ្សព្វផ្សាយសារនេះ ។ សកម្មភាពទាំងនេះ អាចរួមមានការរៀបចំយុទ្ធនាការសម្អាតឆ្នេរ ដោយមានការដឹកនាំពីមន្ត្រីនៅមូលដ្ឋាន ការរៀបចំព្រឹត្តិការណ៍ផ្សារភ្ជាប់ជាមួយនឹងការញែកសំរាម ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ឬការប្តេជ្ញាមិនដុតសំរាមតាមទីវាល និងមិនចោលសំរាមខុសច្បាប់ជាដើម។

*សកម្មភាពសាកល្បងនៅក្រោម៖ ការអប់រំនិងការយល់ដឹង*

## សេចក្តីសន្និដ្ឋាន

លក្ខណៈប្រជាសាស្ត្រ និងនិន្នាការកំណើនសេដ្ឋកិច្ច គួបផ្សំនឹងកំណើនវិស័យទេសចរណ៍ រួមចំណែកយ៉ាងសំខាន់ក្នុងការកំណត់ពីតម្រូវការនៃការគ្រប់គ្រងសំណល់នាពេលបច្ចុប្បន្ន និងអនាគតនៅខេត្តកែប។ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំៗជាងគេនាពេលបច្ចុប្បន្ន ដែលធ្វើឱ្យរាំងស្ទះដល់ការកែលំអការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែប មិនមែនជាបញ្ហាប្រឈមពាក់ព័ន្ធនឹងបច្ចេកវិទ្យានោះឡើយ ប៉ុន្តែពាក់ព័ន្ធនឹងអភិបាលកិច្ចជារួមរបស់វិស័យនេះ។បញ្ហាប្រឈមដ៏សំខាន់

នៅក្នុងវិស័យអភិបាលកិច្ចនេះនៅតែបន្តមានទៀតដែលនាំឱ្យមានការកំណត់មិនច្បាស់លាស់ពីផ្នែកថវិកា និងសមត្ថកិច្ចគ្រប់គ្រង ក៏ដូចជានាំឱ្យមានការធ្វើការងារត្រួតគ្នា និងការភាន់ច្រឡំអំពីភារកិច្ច និងតួនាទីរបស់សមត្ថកិច្ចគ្រប់កម្រិតក្នុងការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់។

ទស្សនទានណែនាំមួយចំនួន ដែលនៅតែមានសារៈសំខាន់ និងគួរតែយកចិត្តទុកដាក់ រួមមាន៖

- ការធ្វើវិមជ្ឈការពេញលេញនិងការអនុលោមទាំងស្រុងតាមអនុក្រឹត្យលេខ ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការកសាងសមត្ថភាពមន្ត្រីមូលដ្ឋាន ដើម្បីធានាថា ពួកគាត់អាចបំពេញការងារគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាព
- ការរៀបចំយន្តការដែលធានាឱ្យមានលំហូរធនធានសម្រាប់ការវិនិយោគចាំបាច់ក្នុងវិស័យនេះ
- ការបង្កើតក្របខណ្ឌក្របខ័ណ្ឌរឹងមាំ រួមមានវិធានការសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ ការប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ ដែលអនុញ្ញាតឱ្យមានការតាមដានការបំពេញការងារផ្នែកបច្ចេកទេស និងគ្រប់គ្រង។

ចំណុចខ្លាំងនៃគំនិតផ្តួចផ្តើមនេះ គឺការប្រមូលផ្តុំទស្សនទានចម្រុះពីសំណាក់រដ្ឋាភិបាលនៅកម្រិតផ្សេងៗគ្នា និងបទពិសោធន៍នៃការចូលរួមរបស់ អង្គការមូលនិធិអាស៊ី ពីមុនមកនៅកម្ពុជាលើការងារពាក់ព័ន្ធនឹងគោលនយោបាយស្តីពីការគ្រប់គ្រងសំណល់រឹង។ ការវិភាគក្នុងឯកសារគោលនយោបាយសង្ខេបនេះ ផ្តល់នូវចំណុចចាប់ផ្តើម សម្រាប់ការពិភាក្សាអំពីឱកាសឆ្លើយតបចំពោះបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងសំណល់រឹងក្នុងកុង្រកែប និងស្នើឡើងនូវអនុសាសន៍គោលនយោបាយសំខាន់ៗទាក់ទងនឹងទស្សនទានសាកល្បងទាំង ០៥ ខាងលើដែលអាចយកទៅអនុវត្តក្នុងក្រុងដទៃនៅប្រទេសកម្ពុជា។

# ឯកសារយោង


Barboza, L. G. A., Vethaak, A. D., Lavorante, B. R., Lundebye, A. K., & Guilhermino, L. (2018). Marine Microplastic Debris: An Emerging Issue for Food Security, Food Safety and Human Health. *Marine pollution bulletin*, 133, 336-348.

Dri, M., Canfora, P., Antonopoulos, L., & Gaudillat, P. (2018). *Best Environmental Management Practice for the Waste Management Sector*. Retrieved from https://ec.europa.eu/jrc/en/publication/eur-scientific-and-technical-research-reports/best-environmental

Engel, H., Stuchtey, M., & Vanthournout, M. (2016). *Managing Waste in Emerging Markets*. Retrieved from https://www.mckinsey.com/business-functions/sustainability/our-insights/managing-waste-in-emerging-markets

ETAGIW Consortium. (2012). *Preparing a Waste Management Plan: A Methodological Guidance Note*. Retrieved from https://ec.europa.eu/environment/waste/plans/pdf/2012_guidance_note.pdf

Ferronato, N., & Torretta, V. (2019). Waste Mismanagement in Developing Countries: A Review of Global Issues. *International journal of environmental research and public health*, 16(6).

Hansen, W., Christopher, M., & Verbuecheln, M. (2002). *EU Waste Policy and Challenges for Regional and Local Authorities*. Retrieved from https://www.ecologic.eu/sites/files/download/projekte/1900-1949/1921-1922/1921-1922_background_paper_waste_en.PD

Lohri, C. R., Camenzind, E. J., & Zurbrügg, C. (2014). Financial Sustainability in Municipal Solid Waste Management – Costs and Revenues in Bahir Dar, Ethiopia. *Waste management*, 34(2), 542–552.

Marine Litter Solutions. (2019). *What Causes Marine Litter?* Retrieved from https://www.marinelittersolutions.com/about-marine-litter/what-causes-marine-litter/

Modak, P., Pariatamby, A., Seadon, J., Bhada-Tata, P., Borongan, G., Thawn, N. S., & Lim, M. B. (2017). *Asia waste management outlook*. Retrieved from http://wedocs.unep.org/bitstream/handle/20.500.11822/27289/Asia_WMO.pdf?sequence=1&isAllowed=y

Olukanni, D. O., & Nwafor, C. O. (2019). Public-Private Sector Involvement in Providing Efficient Solid Waste Management Services in Nigeria. *Recycling*, 4(2).

PDoE. (2018). *2018 Data and Information about Solid Waste Management in Kep (Khmer)*.

PDoT. (2019). *Data Collection on Hotels, Guesthouses, Bungalows, Restaurants, and Other Entertainment Facilities for the First Quarter of 2019 (Khmer)*.

Pech, S. (2018). *Waste Production Continues to Rise*. Retrieved from https://www.khmertimeskh.com/539241/waste-production-continues-to-rise/

SALGA, & Department of Environmental Affairs of Republic of South Africa. (2015). *Defining the Role of Local Government in Environmental Management and Establishing the Costs of Performing Environmental Management Functions*.

Sang-Arun, J., & Chau, K. H. (2019). *A Guide for Technology Selection and Implementation of Urban Organic Waste Utilization Projects in Cambodia*. Retrieved from https://www.files.ethz.ch/isn/143827/IGES2011-Promoting-OWU-Cambodia-printed.pdf

Singh, R. K., Premakumara, D. G. J., Yagasa, R., & Onogawa, K. (2018). *State of Waste Management in Phnom Penh, Cambodia*. Retrieved from https://www.ccet.jp/sites/default/files/2018-07/State%20of%20Waste%20Management%20in%20Phnom%20Penh%2C%20Cambodia%20_w

UNDP. (2019). *Factsheet: Status of Solid Waste Management in Cambodia*. Retrieved from https://www.kh.undp.org/content/cambodia/en/home/library/environment_energy/factsheet--status-of-solid-waste-management-in-cambodia.html

Yoshino, N., & Taghizadeh-Hesary, F. (2018). *Sustainable Funding Schemes for the Development of Waste Management Projects in Asia*. Retrieved from https://www.asiapathways-adbi.org/2018/06/sustainable-funding-schemes-for-the-development-of-waste-management-projects-in-asia/

### អ្នកនិពន្ធ៖

Christopher Godlove

ប៉ាក់ គឹមជឿន



### ការគាំទ្រផ្នែកថវិកា៖

អង្គការមូលនិធិអាស៊ី



© កម្មសិទ្ធិបញ្ញា ២០២០ អង្គការមូលនិធិអាស៊ី និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

សិទ្ធិទាំងអស់ត្រូវបានរក្សា។ មិនមានផ្នែកណាមួយនៃរបាយការណ៍នេះ អាចត្រូវបានរៀបរៀងឡើងវិញដោយមិនមានការអនុញ្ញាតពីអង្គការមូលនិធិអាស៊ី និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនោះឡើយ។



### សេចក្តីថ្លែងអំណរគុណ

អង្គការមូលនិធិអាស៊ី សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអ្នកប្រឹក្សាយោបល់របស់យើង រួមមាន លោក Christopher Godlove និងលោកបណ្ឌិត ប៉ាក់ គឹមជឿន ក្នុងការរៀបចំចងក្រងរបាយការណ៍សិក្សាវិសាលភាព និងឯកសារសង្ខេបគោលនយោបាយនេះ និងលោកបណ្ឌិត សេង ប៊ុនរិទ្ធិ សម្រាប់ការផ្តល់ជាដំបូន្មានផ្នែកបច្ចេកទេស និងធាតុចូល។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណចំពោះអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកប្រកបដោយកិច្ចសហការដល់ការសិក្សា។ យើងខ្ញុំសូមគោរព និងកោតសរសើរយ៉ាងខ្លាំង ចំពោះការណែនាំដែលមិនអាចកាត់ថ្លៃបាន មតិយោបល់ និងឆន្ទៈក្នុងការពិនិត្យមើលនូវភាពត្រឹមត្រូវនៃទិន្នន័យ។

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកដ៏សំខាន់របស់សហការី អង្គការមូលនិធិអាស៊ី ដែលបានពិនិត្យ និងផ្តល់ជាមតិយោបល់ល្អៗលើរបាយការណ៍សិក្សាវិសាលភាព និងឯកសារសង្ខេបគោលនយោបាយនេះ។

ជាចុងកោយ អង្គការមូលនិធិអាស៊ី សូមថ្លែងអំណរគុណចំពោះអ្នកជំនាញដែលក្រុមការងារស្រាវជ្រាវបានជួបពិភាក្សាយោបល់ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងខេត្តកែបដែលជាតំបន់ក្រុមការងារចុះធ្វើការសិក្សា។ ក្រុមការងារ ពិតជាមិនអាចរៀបចំរបាយការណ៍សិក្សាវិសាលភាពនិងឯកសារសង្ខេបគោលនយោបាយនេះបាននោះទេ ប្រសិនបើមិនមានការលះបង់ពេលវេលា ការចែករំលែកចំណេះដឹង និងព័ត៌មានពីអ្នកជំនាញ និងអ្នកពាក់ព័ន្ធទាំងអស់។




**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

អាសយដ្ឋានៈ ជាន់ទី ៣ អគារមរតកតេជោ ដីឡូលេខ៥០៣
ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទៈ (+៨៥៥) ៨៩ ២១៨ ៣៧០
គេហទំព័រៈ http://ncsd.moe.gov.kh/

**ក្រសួងបរិស្ថាន**

អាសយដ្ឋានៈ អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់
ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទៈ (+៨៥៥) ២៣ ២១៣ ៩០៨ / ២២០ ៣៦៩
គេហទំព័រៈ https://www.moe.gov.kh/

គជអប
NCDD

**លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

អាសយដ្ឋានៈ ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ (អគារ T) មហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទៈ (+៨៥៥) ២៣ ៧២០ ០៣៨ / ៧២០ ០៦១
គេហទំព័រៈ http://ncdd.gov.kh/

The Asia Foundation

**អង្គការមូលនិធិអាស៊ី**

អាសយដ្ឋានៈ ផ្ទះលេខ ៥៩ ផ្លូវ ឧកញ៉ាពេជ្រ (ផ្លូវ ២៤២)
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទៈ (+៨៥៥) ២៣ ២១០ ៤៣១
គេហទំព័រៈ https://asiafoundation.org/